multicultural health communication

NSW GOVERNMENT Health

Khmer
[DOH-7175]

# ជម្ងឺ Psittacosis

## Psittacosis

### តើជម្ងឺ Psittacosis ជាអ្វី?

- ជម្ងឺ Psittacosis ជាជម្ងឺមួយមិនសូវសំបូរប៉ុន្មានទេ ច្រើនតែឆ្លងពីសត្វបក្សីមកមនុស្ស។ ជម្ងឺនេះបង្ក ដោយបាក់តេរីមួយប្រភេទ ឈ្មោះថា Chlamydia psittaci ។

### តើជម្ងឺនេះឆ្លងយ៉ាងដូចម្ដេច?

- ជាទូទៅការចំលងរោគច្រើនកើតមាននៅពេលមនុស្សដកដង្ហើមចូលនូវមេរោគបាក់តេរីនេះ ច្រើនតែមកពីកំទេច លាមកស្ងួតរបស់បក្សីដែលមានជម្ងឺ ។ មនុស្សក៏អាចឆ្លងតាមរយៈការ ប៉ះពាល់រវាងមាត់និងចំពុះ (ថើប) ជាមួយបក្សី ឬ តាមរយៈការចាប់កាន់ស្លាប ឬជាលិកាបក្សីដែលមានមេរោគ នេះ។ ជម្ងឺ Psittacosis មិនត្រូវបានគេបង្ហាញថា អាចចំលងពីមនុស្សទៅមនុស្សបានទេ។
- រាល់បក្សីទាំងអស់ងាយឆ្លងជម្ងឺនេះណាស់ ប៉ុន្តែបក្សីចិញ្ចឹម (ឧទាហរណ៍ សេក, សេកតូចៗ (parakeets), cockatiels) និងបក្សីផ្សេងៗទៀត (ទា និង មាន់បារាំង) ជាទីបំផុត គឺជាអ្នកចំលង មេរោគទៅមនុស្សញឹកញាប់។
- អ្នកដែលប្រឈមនឹងការឆ្លងជម្ងឺ psittacosis នេះជាងគេបំផុត គឺអ្នកប៉ះពាល់ផ្ទាល់ជាមួយនឹងបក្សីតាម រយៈការងារ ឬ ការលេងកំសាន្ត។ ឧទាហរណ៍ ម្ចាស់បក្សី, និយោជិត ក្នុងហាងលក់សត្វចិញ្ចឹម, ពេទ្យសត្វ ឬ អ្នកដែលធ្វើសាច់បក្សី ។

### តើរោគសញ្ញានៃជម្ងឺ Psittacosis មានអ្វីខ្លះ?

- រយៈពេលរវាងការប៉ះពាល់របស់មនុស្សជាមួយបាក់តេរី និង ការវិវឌ្ឍចេញរោគសញ្ញាប្រែប្រួល ប្រមាណពី ៤ ទៅ ១៥ ថ្ងៃ ។
- បុគ្គលមានជម្ងឺ Psittacosis ច្រើនកើតជម្ងឺដូចផ្ដាសាយ (flu-like illness) ដោយមានការឡើងកំដៅ ខ្លួនភ្លាមៗ, រងាញាក់, ឈឺក្បាល ខ្សោយកំលាំង និង ឈឺចាប់សាច់ដុំ។ ពួកគេថែមទាំងក្អកស្ងួត ឈឺដើមទ្រូង និង ពិបាកដកដង្ហើម (feel breathless) ផងដែរ។ ក្នុងករណីធ្ងន់ធ្ងរ ជម្ងឺហើមសួត នឹងកើតឡើង។

### តើគេធ្វើរោគវិនិច្ឆ័យ និង ព្យាបាលជម្ងឺ Psittacosis យ៉ាងដូចម្ដេច?

- ប្រសិនបើវេជ្ជបណ្ឌិតគិតថាមនុស្សណាម្នាក់មានជម្ងឺ psittacosis នេះ គេអាចធ្វើតេស្តឈាមដើម្បី បញ្ជាក់ពីរោគវិនិច្ឆ័យ។ ការថតមើលទ្រូងដោយកាំរស្មីអ៊ិច ជាញឹកញាប់បង្ហាញឲ្យឃើញថា ជាជម្ងឺហើមសួត។

- ជម្ងឺ Psittacosis ត្រូវព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិច ការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិចនេះត្រូវបន្ត ជាប់រហូត សំរាប់រយៈពេល ២ សប្តាហ៍ ។
- ជាការសំខាន់ណាស់ដែលគេត្រូវព្យាយាមកំណត់ថាតើការចំលងរោគចេញមកពីណា ។ មនុស្សដទៃទៀត ដែលប្រហែលជាបានប៉ះពាល់ផ្ទាល់ជាមួយបក្សីមានជម្ងឺ គួរតែត្រូវគេពន្យល់ណែនាំឲ្យដឹងពីរោគសញ្ញានៃ ជម្ងឺនេះ។ គេគួរព្យាបាលបក្សី និង ធ្វើការសំអាតបរិស្ថានរបស់វាដោយប្រើថ្នាំសំលាប់មេរោគដើម្បីបង្ការ មិនឲ្យមានការចំលងរោគដល់មនុស្ស ឬ បក្សីដទៃទៀត។

## តើខ្ញុំធ្វើដូចម្តេចដើម្បីឲ្យដឹងថាបក្សីមានជម្ងឺឬអត់?

- ចំពោះបក្សីរោគសញ្ញានៃជម្ងឺអាចប្រែប្រួលពីការគ្មានអ្វីសោះទៅជាជម្ងឺមានគ្រោះថ្នាក់ដល់ជីវិត។ បក្សី ឈឺអាចមានរោគសញ្ញាផ្សេងៗដូចជា រាករូស, ខ្សោយកំលាំង, ជ្រុះរោម, មិនស៊ីអាហារ និង ហៀរ ទឹកភ្នែក ឬ សំបោរ។ ប្រសិនបើមានការសង្ស័យ គេអាចឲ្យបសុពេទ្យធ្វើការពិនិត្យបក្សីរបស់អ្នក។ បក្សី មានជម្ងឺចាំបាច់ត្រូវទទួលការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិច ហើយត្រូវដាក់ឲ្យបក្សីនៅដាច់តែឯង ហើយក៏ត្រូវកំចាត់មេរោគនៅក្នុងទ្រុងបក្សីឲ្យបានស្អាតដែរ។
- ដោយសារតែវាជាការពិបាកក្នុងការដឹងថា តើបក្សីមួយក្បាលមានឬគ្មានជម្ងឺនោះ លោកអ្នកត្រូវអនុវត្ត អនាម័យល្អតឹងតែង រួមមានការលាងដៃនៅពេលប៉ះពាល់ឬស្ទាបអង្អែលបក្សីចិញ្ចឹម។ ជៀសវាងការ ថើប (មាត់ទល់នឹងជំពុះ) ជាមួយបក្សីចិញ្ចឹមលេង។
- សត្វបក្សីគួរតែត្រូវគេទុកឲ្យនៅក្នុងទ្រុងស្អាតល្អ, មានទំហំទូលាយទ្រាប់ពីក្រោមដោយក្រដាសកាសែត ដែលគេអាចប្តូរចេញបានញឹកញាប់។ មិនត្រូវទុកឲ្យលាមកបក្សីកើនឡើង ហើយឡើងក្រៀមស្ងួតនោះទេ ហើយមិនត្រូវទុកឲ្យធូលីនៃលាមកនេះរសាត់តាមខ្យល់ឡើយ។ សូមបាញ់ទឹកបនើ្សមលាមកបក្សីឬទ្រុង បក្សីជាមុន មុននឹងធ្វើការសំអាត។
- គេគួរតែទទួលយកបក្សីទាំងឡាយណាដែលចេញមកពីកន្លែងថែរក្សាបក្សី (aviary) ឬហាងលក់សត្វ ចិញ្ចឹមដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។

ព័ត៌មានបន្ថែម- **Public Health Units in NSW**

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិត មន្ទីរសុខភាពសាធារណៈតាមតំបន់ ឬមណ្ឌលសុខភាពក្នុង សហគមន៍របស់លោកអ្នក។ សូមមើលនៅត្រង់កន្លែង ‘NSW Government’ នៅផ្នែកខាងមុខនៃសៀវភៅ White Pages។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**